# ឍ

**ឍ** ព្យញ្ជនៈទី ៤ ក្នុងវគ្គទី ៣ ជាមុទ្ធជៈ មានសំឡេងកើតក្នុងក្បាល និងមានសំឡេងលាន់ឮទៅខាងក្នុងក្បាល ផ្សេងពីសំឡេង *ធ* ទន្តជៈ ដែលមានស្នូរចេញត្រង់ទ្រទល់ធ្មេញ, សំ. បា. អ. ប. ឌ្ហ: ផ្សេងពីសំឡេង *ធ្ហ:* ទន្តជៈ, ជា ធនិត-ឃោសៈ របស់ ឌ: ជាសិថិល-ឃោសៈ (ត្រូវអានជា ឌ៌: ឌ្ហ៌: កុំឲ្យដូច ទ: ធ្ហ:) ។ ព្យញ្ជនៈ *ឍ* នេះ ក្នុងភាសាសំស្រ្កឹត ឃើញមានប្រើជា *ដើមពាក្យ* ឬ *បទពាក្យ* ខ្លះ តែមានតិច-ណាស់; ខាងភាសាបាលី មិនប្រទះឃើញមានប្រើ, បើដាក់រៀងត្រង់កណ្ដាលឬត្រង់ខាងចុងនៃពាក្យឯទៀតនោះ ឃើញមានប្រើក្រៃល ដូចជា *គុណវុឌ្ឍិ* សេចក្ដីចម្រើនដោយគុណ; *ធនវុឌ្ឍិ* សេចក្ដីចម្រើនដោយទ្រព្យ; *យសវុឌ្ឍិ* សេចក្ដីចម្រើនដោយយស; *លាភវុឌ្ឍិ* សេចក្ដីចម្រើនដោយលាភ; *សិរីវុឌ្ឍិ* សេចក្ដីចម្រើនដោយសិរី; *វុឌ្ឍាការ* អាការនៃសេចក្ដីចម្រើន; *វុឌ្ឍិ* សេចក្ដីចម្រើន, ការថុះថាល, លូតលាស់; *អឌ្ឍចន្ទ* ព្រះចន្ទមួយចំហៀង; *អឌ្ឍភាគ* កន្លះភាគ; *អឌ្ឍមាស* កន្លះខែ; *អឌ្ឍរត្តិ* (សំ. *អទ៌្ធរាត្រ* ឬ *អទ៌្ធរាត្រី*) ពាក់-កណ្ដាលយប់; *អាយុវឌ្ឍនៈ* ឬ *អាយុវុឌ្ឍិ* សេចក្ដីចម្រើនអាយុ ។ល។ ឯភាសាខ្មែរយើង មិនមានពាក្យប្រើសោះឡើយ; តែក្នុងទីនេះ យើងយកភាសាសំស្រ្កឹត ៤ ពាក្យមករៀបរៀង, បើទោះបីមិនត្រូវការប្រើ, ក៏ជាប្រយោជន៍ឲ្យអក្សរ *ឍ* មានពាក្យខ្លះ កុំឲ្យទទេពេក ។

**ឍាមរា** (ឍាមៈរា) *ន.* (សំ.) ក្ងាន; ហង្ស ។

**ឍាល** *ន.* (សំ.) ស្នប់; ខែល ។

**ឍាលិន** *ន.* (*សំ. ឍាលិន៑*) អ្នកមានខែល, អ្នកកាន់ខែល, ទាហានខែល គឺអ្នកចម្បាំងខែលដែលហ្វឹកហាត់ចួលច្បាំងកាន់ខែលសម្រាប់ភាំងគ្រឿងសស្ត្រាវុធនៃបច្ចាមិត្រ មិនឲ្យប៉ះពាល់ត្រូវខ្លួន ។

**ឍុណ្ឌិ** *ន.* (សំ.) ព្រះគណេស ។